# សិទ្ធិស្ត្រីក្នុងវិស័យការងារ

(ចង្វាក់ កន្ទ្រឹម) កែសម្រួលដោយក្រសួងវប្បធម៌ (៥)

១- ហៃជនប្រុសស្រី  លើភពផែនដី  រស់ដោយការងារ
សិទ្ធិនេះជួយស្ត្រី  បានសុខសោភា  ពួកយើងរាល់គ្នា
ចាំក្នុងចិន្តា ។

២- សិទ្ធិការងារនោះ  មិនអាចដូរដោះ  ផ្ទេរលក់ឡើយណា
ស្ត្រីមានឱកាស  ដូចប្រុសគ្រប់គ្នា  កិច្ចការនានា
បានល្អប្រពៃ ។

៣- មានអាជីពជាក់  សិទ្ធិឡើងបុណ្យស័ក្តិ  ជ្រើសដោយសេរី
ស្មេរភាពការងារ  មានប្រាក់កម្រៃ  សុក្រិតថ្លាថ្លៃ
អចិន្ត្រៃយ៍ផង ។

៤- សិទ្ធិមួយស័ក្តិសម  នៅក្នុងសង្គម  ប្រយោជន៍ចំបង
ពេលចូលនិវត្តន៍  ជរាបាក់បម  ឈប់សម្រាកផង
ប្រាក់កាសក៏មាន ។

៥- ពេលមានពោះពង់  រដ្ឋជួយទ្រទ្រង់  ពុំដែលខកខាន
ជួយសុខភាព  ថវិកាក៏មាន  ទៅតាមលំអាន
នៃច្បាប់សង្គម ។

៦- រដ្ឋចេញបំរាម  ច្បាប់ជួយឃាត់ហាម  មិនដាក់ទណ្ឌកម្ម
ទៅលើការងារ  ដោយហេតុពុំសម  បណ្តេញពីក្រុម
កុំរើសអើងស្ត្រី ។

៧- សិទ្ធិការងារនេះ  ដូចតារារះ  បំភ្លឺលោកកិយ
ជួយលើកតំកើន  តម្លៃស្ត្រី  សោភាប្រឹមប្រិយ
អោយរស់ថ្លៃថ្លា ។

៨- កុំបីរើសអើង    ជួយស្ត្រីយើង    ជាមនុស្សដូចគ្នា
បើមានតែប្រុស    មេឃាពិតជា    ដូចព្រះសុរិយា
ពុំមានព្រះច័ន្ទ ។

៩- សិទ្ធិធ្វើការងារ    ស្រីប្រុសស្មើគ្នា    កិច្ចការស្រាលធ្ងន់
ជាស្ពានជីវិត    បង្កើនទ្រព្យធន    សុខសាន្តភារម្យ
រុងរឿងតទៅ ។